**Peace Corps CAMBODIA**





# ខួបគម្រប់១០ឆ្នាំ
# នៃភ្នាក់ងារ ភីសខ័រ ប្រចាំកម្ពុជា










## សារពីនាយិកាភ្នាក់ងារភីសខ័រ ប្រចាំប្រទេស



លោកស្រី ស៊ូសាន ដ្វាយើ
អតីតអ្នកស្ម័គ្រចិត្តភីសខ័រនៅ
ប្រទេសយូហ្គេនដាពីឆ្នាំ ១៩៩២-១៩៩៤

ភ្នាក់ងារភីសខ័រសហរដ្ឋអាមេរិកកំពុងប្រារពខួប១០ឆ្នាំនៅប្រទេសកម្ពុជា។ ក្នុងកំឡុងពេលនេះអ្នកស្ម័គ្រចិត្តភីសខ័រជាង៤០០នាក់ បានមកធ្វើការស្ម័គ្រចិត្តនៅក្នុងសហគមន៍ជាច្រើននៅក្នុងខេត្តចំនួន១៦ក្នុងប្រទេសកម្ពុជា។ ដើម្បីធ្វើអោយសមស្របទៅតាមវិស័យអាទិភាពរបស់ក្រសួងអប់រំយុវជន និងកីឡា និងក្រសួងសុខាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជា ភ្នាក់ងារភីសខ័រ ប្រចាំកម្ពុជា អនុវត្តកម្មវិធី២គឺ ១) ការបណ្តុះបណ្តាលគ្របង្រៀន និងការបង្រៀនភាសាអង់គ្លេស ២) ការអប់រំសុខភាពសហគមន៍។

តាមរយៈកម្មវិធីទាំងពីរនេះ និងគម្រោងតូចៗមួយចំនួនទៀតអ្នកស្ម័គ្រចិត្ត ភីសខ័រ បានបម្រើប្រជាជនខ្មែររាប់ម៉ឺននាក់។ អ្នកស្ម័គ្រចិត្តភីសខ័រធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រជាជននៅក្នុងសហគមន៍ដើម្បីលើកកម្ពស់ការស្វែងយល់ពីគ្នាទៅវិញទៅមកអោយបានច្រើនរវាងជនជាតិខ្មែរ និងជនជាតិអាមេរិកតាមរយៈការនិយាយភាសាខ្មែរ សិក្សាអំពីវប្បធម៌ខ្មែរ និងរស់នៅក្នុងប្រទេសកម្ពុជារយៈពេល២ឆ្នាំ។

រំលឹកទៅដល់កាលពី១០ឆ្នាំមុន យើងពិតជាមានការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូការងារនៃរាជរដ្ឋាភិបាលកម្ពុជានៅថ្នាក់ ភូមិ ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ រួមទាំងក្រសួងអប់រំយុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ដែលបានផ្តល់ការគាំទ្រដល់សកម្មភាពការងាររបស់យើង។ យើងក៏សូមថ្លែងអំណរគុណដល់ដៃគូការងាររបស់អ្នកស្ម័គ្រចិត្តភីសខ័រ ដែលបានជួយអោយការងារអ្នកស្ម័គ្រចិត្តបានជោគជ័យ និងក្រុមគ្រួសារខ្មែរដែលបានមើលថែរក្សាអ្នកស្ម័គ្រចិត្តរបស់យើងយ៉ាងយកចិត្តទុកដាក់បំផុត។

នាងខ្ញុំពិតជាមានមោទនៈភាពខ្លាំងណាស់ក្នុងនាមជាអ្នកតំណាងបេសកកម្មរបស់ភ្នាក់ងារ ភីសខ័រ ក្នុងការលើកកម្ពស់សន្តិភាព និងមិត្តភាពជាសកលនៅក្នុងព្រះរាជាណាចក្រអច្ឆរិយៈមួយនេះ។

ស៊ូសាន ដ្វាយើ
នាយិកាប្រចាំប្រទេស

## បេសកកម្មរបស់ភ្នាក់ងារ ភីសខ័រ

ដើម្បីបង្កើតមិត្តភាព និងសន្តិភាពពិភពលោកដោយបំពេញនូវគោលបំណងចំនួន៣៖

១ ផ្តល់អ្នកស្ម័គ្រចិត្តទាំងបុរស និងស្ត្រីដែលបានទទួលការបណ្តុះបណ្តាលទៅជួយប្រជាជននៅក្នុងបណ្តាប្រទេសដែលចាប់អារម្មណ៍លើភ្នាក់ងារ ភីសខ័រ។

២ ជួយអ្នកស្ម័គ្រចិត្តអាមេរិកាំងអោយមានការយល់ដឹងកាន់តែប្រសើរអំពីប្រជាជនទាំងឡាយដែលពួកគេធ្វើការជាមួយ។

៣ ជួយបង្កើនការយល់ដឹងរបស់ប្រជាជននៅជុំវិញពិភពលោកអោយបានយល់ដឹងកាន់តែប្រសើរអំពីជនជាតិអាមេរិកាំង។

## កម្មវិធីនៅប្រទេសកម្ពុជា

### ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស



អ្នកស្ម័គ្រចិត្ត ភីសខ័រ បង្រៀននៅអនុវិទ្យាល័យ វិទ្យាល័យ និងសាលាគរុកោសល្យ អ្នកស្ម័គ្រចិត្ត ភីសខ័រ ទាំងអស់បង្រៀនជាមួយគ្រូដៃគូជនជាតិខ្មែរ ហើយវិធីសាស្ត្រនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់សិស្សានុសិស្សអោយមានការចូលរួមនៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជួយបង្កើនចំណេះដឹងផ្នែកភាសាអង់គ្លេស និងជំនាញក្នុងការគ្រប់គ្រងថ្នាក់រៀនរបស់គ្រូជនជាតិខ្មែរទៀតផង។

### ការអប់រំសុខភាពសហគមន៍



គោលបំណងរបស់កម្មវិធីនេះគឺដើម្បីជួយលើកកម្ពស់សុខភាព និងសមត្ថភាពរបស់ប្រជនជននៅក្នុងសហគមន៍កម្ពុជាជាពិសេសស្ត្រីនិងកុមារក្នុងការឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាពផ្សេងៗ។

អ្នកស្ម័គ្រចិត្តភីសខ័រ ទាំងអស់ធ្វើការជាមួយបុគ្គលិកមណ្ឌលសុខភាព អ្នកស្ម័គ្រចិត្តសុខភាពភូមិ និងសាលារៀនមួយចំនួនដើម្បីជួយបង្កើនសម្ថភាពរបស់ប្រជាជនក្នុងការឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាពផ្សេងៗរបស់ពួកគេ។

## បទពិសោធន៍រស់នៅជាមួយគ្រួសារខ្មែរ



អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី៨ ឈ្មោះ ឡូរ៉ា ហារីស និងម្តាយធម៌របស់គាត់ នៅខេត្តកោះកុង ឆ្នាំ ២០១៤-២០១៦

"ខ្ញុំរស់នៅលើកោះមួយជាមួយម្តាយខ្មែររបស់ខ្ញុំ។ យើងបានទៅចូលរួមពិធីរៀបអាពាហ៍ពិពាហ៍របស់គេជាច្រើនយើងបានមើលផ្កាយ សួរសំនួរអំពីសង្គ្រាម ជជែកគ្នាលេងអំពីគោលបំណងនៃជីវិតមនុស្ស និងសត្វសមុទ្រ យើងបានបោកខោអាវ ញ៉ាំអាហារ ចំអិនអាហារ និងយំជាមួយគ្នា។ ខ្ញុំកំពុងរៀនចំអិនម្ហូបខ្មែរ ហើយគាត់កំពុងរៀនចំអិនអាហារអាមេរិកផងដែរ។ គាត់ចាត់ទុកខ្ញុំដូចជាកូនស្រីគាត់ដែរ។ ខ្ញុំតែងតែគិតថាខ្ញុំនឹងត្រូវរៀនភាសាថ្មីមួយ ហើយជួបង្រៀនភាសាអង់គ្លេស និងមានមិត្តភក្តិថ្មីៗ។ ខ្ញុំមិនដែលដឹងសោះថាខ្ញុំនឹងមានម្តាយទីពីរនោះទេ។ ខ្ញុំនិងម្តាយខ្ញុំមានការយល់ពីគ្នា តាមរយៈការប្រាស្រ័យទាក់ទងគ្នានិងការគិតរបស់យើង ហើយវាគឺជារឿងមួយដ៏អស្ចារ្យ ។ ខ្ញុំបានរៀនសូត្រយ៉ាងច្រើនពីគាត់ដូចជា រៀនក្រោកឈរដោយម៉ឺងម៉ាត់ដើម្បីខ្លួនឯងប៉ុន្តែក្នុងលក្ខណៈទន់ភ្លន់ចិត្តល្អ និង អធ្យាស្រ័យខ្ពស់ រៀនអំពីគំនិតរបស់គាត់ពាក់ព័ន្ធនឹងទំនាក់ទំនងយែនឌ័រ និងការចិញ្ចឹមកូន ។"

## រូបភាពអ្នកស្ម័គ្រចិត្តភីសខ័រកម្ពុជា




**Peace Corps CAMBODIA**

## ភ្នាក់ងារភីសខ័រប្រចាំកម្ពុជា


ប្រអប់សំបុត្រលេខ ២៩៥៣ ភ្នំពេញ៣
ផ្ទះលេខ ៧A ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ៖ +៨៥៥ ២៣-២២២-៩០១
ទូរសារ៖ +៨៥៥ ២៣-២២២-៩០៣
អ៊ីមែល៖ info@kh.peacecorps.gov
គេហទំព័រ៖ http://peacecorps.gov/cambodia

Cambodia.Peacecorps
PeacecorpsCambodia
PeacecorpsCambo


PEACE CORPS CAMBODIA . SEPTEMBER 2016

Peace Corps
CAMBODIA

“ ខ្ញុំសូមសន្យាថានឹងចែករំលែកវប្បធម៌របស់ខ្ញុំដោយបើកចិត្តអោយទូលាយ។ ខ្ញុំសូមសន្យាថានឹងបង្កើនការយល់ដឹងអំពីប្រជាជនកម្ពុជាដោយភាពឆ្នៃប្រឌិត ដោយការគោរពវប្បធម៌ និងដោយការគោរព។ ខ្ញុំនឹងជំនះឧបសគ្គទាំងឡាយក្នុងពេលបំរើការងារដោយភាពអំណត់ ការដាក់ខ្លួន និងការតាំងចិត្តខ្ពស់។ ខ្ញុំនឹងប្រកាន់ខ្ជាប់នូវបេសកកម្មក្នុងការលើកកម្ពស់មិត្តភាព និងសន្តិភាពជាសកលដ៏រាបណាខ្ញុំជាអ្នកស្ម័គ្រចិត្តភីសខ័រ និងបន្ទាប់ពីខ្ញុំបញ្ចប់ពីតួនាទីជាអ្នកស្ម័គ្រចិត្តភីសខ័រ។ ”

--ពាក្យសម្បថរបស់ភ្នាក់ងារភីសខ័រ

# ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំរបស់ភ្នាក់ងារភីសខ័រប្រចាំកម្ពុជា

## ១៩៩៤



### ចុះហត្ថលេខលើកិច្ចព្រមព្រៀង

នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៩៤ នៅរដ្ឋធានីវ៉ាស៊ីនតោនឌីស៊ី រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីអនុញ្ញាតអោយភ្នាក់ងារភីសខ័រអនុវត្តកម្មវិធីនៅព្រះរាជាណាចក្រកម្ពុជា។

## ២០០៦

Peace Corps

### បើកការិយាល័យ

ភ្នាក់ងារភីសខ័រ បើកការិយាល័យជាផ្លូវការដំបូងនៅក្នុងប្រទេសកម្ពុជា។

Peace Corps

### ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយ ក្រសួងអប់រំ យុវជន និងកីឡា

ភ្នាក់ងារភីសខ័រ ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយក្រសួងអប់រំ យុវជន និងកីឡានៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៦ ដើម្បីចាប់ផ្តើមកម្មវិធី ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស។

## ២០០៧



### ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី១

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេសក្រុមទី១ ចំនួន២៩នាក់ ស្បថចូលបំរើការងារនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៧ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បាត់ដំបង
- កំពង់ចាម
- កំពត
- ព្រៃវែង
- សៀមរាប
- ស្វាយរៀង
- តាកែវ



### អ្នកស្ម័គ្រចិត្តភីសខ័រចូលគាល់ព្រះមហាក្សត្រ

អ្នកស្ម័គ្រចិត្តភីសខ័រ និងនាយកប្រចាំប្រទេសរបស់ភ្នាក់ងារ ភីសខ័រប្រចាំកម្ពុជាចូលគាល់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**

## ២០០៨



### ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី២

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស ចំនួន៣៩នាក់ ស្បថចូលបំរើការងារនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ធំ
- កំពត
- កណ្តាល
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០០៩



### ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី៣

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស ចំនួន៤២នាក់ ស្បថចូលបំរើការងារនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៩ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ធំ
- កំពត
- ភ្នំពេញ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០១០



### ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី៤ និងអ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាពសហគមន៍ក្រុមដំបូង

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៤៩នាក់ ៣១នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ១៨នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ភ្នំពេញ
- ព្រះសីហនុ
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

Peace Corps

### ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយ ក្រសួងសុខាភិបាល

ភ្នាក់ងារភីសខ័រ ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយក្រសួងសុខាភិបាលនៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១០ ដើម្បីចាប់ផ្តើមកម្មវិធី ការអប់រំសុខភាពសហគមន៍។

## ២០១១



### ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី៥

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៥៩នាក់ ៤០នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ១៩នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កណ្តាល
- កោះកុង
- ភ្នំពេញ
- ព្រះសីហនុ
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១២



### ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី៦

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៥៨នាក់ ២៩នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ២៩នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រះសីហនុ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០១៣



### ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី៧

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៤៦នាក់ ២៩នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ១៧នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កណ្តាល
- កោះកុង
- ភ្នំពេញ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១៤



### ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី៨

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៥៣នាក់ ២៩នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ២៤នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប

## ២០១៥



### ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី៩

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៦៣នាក់ ៣៩នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ២៩នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ




### គំនិតផ្តួចផ្តើម ផ្តល់ឱកាសអោយស្ត្រី និងក្មេងស្រីបានចូលសិក្សា

នៅថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៥ លោកជំទាវទី១របស់សហរដ្ឋអាមេរិកបានធ្វើទស្សនៈកិច្ចមកភ្នាក់ងារភីសខ័រប្រចាំកម្ពុជាដើម្បីចាប់ផ្តើម កម្មវិធី គំនិតផ្តួចផ្តើម ផ្តល់ឱកាសអោយស្ត្រី និងក្មេងស្រីបានចូលសិក្សា។

## ២០១៦




### ការមកដល់របស់អ្នកស្ម័គ្រចិត្តភីសខ័រ ក្រុមទី១០

កម្មសិក្សាភីសខ័រក្រុមទី១០ចំនួន ៦៨នាក់ នឹងធ្វើការស្បថចូលបម្រើការងារនៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៦ និងត្រូវបំរើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

Peace Corps
CAMBODIA